# ប្រវត្តិគណបក្ស

ក្រុមស្ថាបនិក **គណបក្សកម្ពុជានិយម** ដឹកនាំដោយលោក **យ៉ែម បុញ្ញឫទ្ធិ** អតីតអ្នកតំណាងរាស្ត្រមណ្ឌលខេត្តព្រៃវែងឆ្នាំ២០០៨ (គណបក្សសិទ្ធិមនុស្ស) និងជាអតីតអ្នកតំណាងរាស្ត្រមណ្ឌលខេត្តព្រៃវែងឆ្នាំ២០១៣ (គណបក្សសង្គ្រោះជាតិ) ដែលមានតួនាទីជាប្រធានគណៈកម្មការទី៧នៃរដ្ឋសភា (គណៈកម្មការអប់រំ-យុវជន-កីឡា ធម្មការ-កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍) និងជាសមាជិកអចិន្ត្រៃយ៍នៃរដ្ឋសភា បានមូលមតិគ្នាសម្រេចបង្កើតគណបក្សនយោបាយនៅឆ្នាំ២០២១ ក្រោយពីការរំលាយគណបក្សសង្គ្រោះជាតិ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧។

គណបក្សនេះបានកំណត់យកថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១ ជាថ្ងៃបង្កើតគណបក្សជាផ្លូវការ ដែលបានសម្រេចដោយក្រុមស្ថាបនិកគណបក្ស និងបន្តបេសកកម្មជាតិពី ៖

- គណបក្សប្រជាធិបតេយ្យ ឆ្នាំ១៩៤៦
- គណបក្សសិទ្ធិមនុស្ស ឆ្នាំ២០០៧
- គណបក្សសង្គ្រោះជាតិ ឆ្នាំ២០១២

ដោយយល់ឃើញថា ក្រោយសម័យមហានគរ "អង្គរ" ប្រទេសកម្ពុជា និងប្រជាពលរដ្ឋខ្មែរ បានឆ្លងកាត់នូវមហាសោកនាដកម្ម ដោយសារសង្គ្រាមផ្ទៃក្នុង និងសង្គ្រាមឈ្លានពានលេបទឹកដីពីសំណាក់បរទេសឥតឈប់ឈរ ដែលបាននាំមកនូវក្តីវិនាសមហន្តរាយ ដល់ជីវិតប្រជាពលរដ្ឋ និងមាតុភូមិកម្ពុជា សឹងតែរលាយរលត់។ ដ្បិតមានកិច្ចព្រមព្រៀងអន្តរជាតិ ស្តីពីកម្ពុជា នៅហ្សឺណែវឆ្នាំ១៩៥៤ និងនៅប៉ារីស៍ឆ្នាំ១៩៩១ក្តី ក៏បញ្ហាប្រឈម និងហានិភ័យ នៅតែអាចកើតមានជាយថាហេតុ។ ហេតុនេះ កិច្ចការពារជាតិ ការពារបូរណភាពទឹកដី និងសិទ្ធិសេរីភាព ដើម្បីប្រជាពលរដ្ឋខ្មែរ ជាគោលបំណង និងជាករណីយកិច្ចចម្បងបំផុតរបស់យើងខ្ញុំ រួមជាមួយពលរដ្ឋខ្មែរគ្រប់រូប។

ដោយយល់ឃើញថា កិច្ចការពារជាតិមាតុភូមិ និងសន្តិភាព ត្រូវការជាចាំបាច់នូវការឯកភាពជាតិ និងការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋ។ ការបែកបាក់ជាតិបានកើតឡើងជាច្រើនលើក រហូតមានការផ្ទុះជាសង្គ្រាមផ្ទៃក្នុងជាតិផងដែរ។ ស្ថានភាពនៃការបែកបាក់ជាតិនេះត្រូវតែបញ្ចប់ ដោយជំនួសមកវិញនូវការផ្សះផ្សាជាតិដើម្បីបង្កើតបាននូវ ស្ថិរភាពផ្ទៃក្នុងជាតិ តាមរយៈការគោរព និងលើកកម្ពស់សិទ្ធិសេរីភាព យុត្តិធម៌ និងផ្តល់សេចក្តីគោរពទុកចិត្តគ្នាទៅវិញទៅមកក្នុងគំនិតស្មារតី ប្រជាធិបតេយ្យ សេរី និងការទទួលខុសត្រូវ ស្របតាមដំណើរនៃពិភពលោកទៅកាន់យុត្តិធម៌ សមភាព និងសេរីភាព ដើម្បីសេចក្តីចម្រើនរុងរឿង និងសន្តិភាព សម្រាប់មនុស្សជាតិ។ គោលការណ៍ទាំងនេះ ត្រូវបានកំណត់រួចហើយក្នុងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងសន្តិភាព រវាងភាគីអន្តរជាតិ និងគ្រប់ភាគីខ្មែរ នាទីក្រុងប៉ារីស៍ ឆ្នាំ១៩៩១ និងក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ដែលត្រូវបានប្រជាពលរដ្ឋខ្មែរគាំទ្រ និងទទួលយកជាឯកច្ឆន្ទជាច្បាប់នយោបាយកំពូលនៃប្រទេសកម្ពុជា។

ដោយយល់ឃើញថា សាកលភាវូបនីយកម្ម នៃពិភពលោកនៅសម័យថ្មីនេះ ជះឥទ្ធិពលអវិជ្ជមាន និងអាចផ្តល់នូវគ្រោះថ្នាក់ជាច្រើនដល់សង្គមជាតិ បានជំរុញឱ្យយើងរួមគ្នាគិតរក្សាការពារ ឯករាជ្យ អត្តសញ្ញាណជាតិ ជីវភាព សេដ្ឋកិច្ចទីផ្សារ របស់យើងជាចាំបាច់បំផុត ដោយរៀបចំ កសាងរដ្ឋទំនើប សង្គមជឿនលឿន មានអារ្យធម៌ថ្លៃថ្នូរ យុត្តិធម៌ សមធម៌ នីតិរដ្ឋ ប្រជាធិបតេយ្យសេរី។

ដោយការប្តេជ្ញាចិត្តដាច់ខាត បម្រើឧត្តមគតិខាងលើនេះ យើងខ្ញុំទាំងអស់គ្នាបានសម្រេចចិត្ត បង្កើតគណបក្សនយោបាយមួយ ដែលមានលក្ខណៈប្រជាធិបតេយ្យសេរី កើតចេញមកពីការប្រមូលផ្តុំអ្នកស្នេហាជាតិ និងអ្នកប្រជាធិបតេយ្យសេរី ស្របតាមឆន្ទៈរបស់ប្រជាពលរដ្ឋខ្មែរ ដែលមានឈ្មោះ និងមានគោលនយោបាយ ដូចតទៅ ៖

គណបក្សនយោបាយនេះមានឈ្មោះថា «**គណបក្សកម្ពុជានិយម**» ហើយត្រូវបានដូរឈ្មោះ ក្នុងឱកាសសមាជវិសាមញ្ញ នៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៥ ជា «**គណបក្សប្រជាធិបតេយ្យជឿនលឿន**» និងអក្សរកាត់ «ប.ជ.ល» ជាអក្សរឡាតាំង «DEMOCRATIC PROGRESSIVE PARTY» និងអក្សរកាត់ «D.P»។

គណបក្សប្រជាធិបតេយ្យជឿនលឿន មានសញ្ញាសម្គាល់ រូបពន្លឺភ្លើងមានកាំរស្មីលើជើងទម្រ នៅចំកណ្តាលចតុកោណស្មើពណ៌ខៀវ ៖

- អក្សរកាត់ **ប.ជ.ល** និងអក្សរ D.P នៅលើជើងទម្រ
- អក្សរ **គណបក្សប្រជាធិបតេយ្យជឿនលឿន** នៅខាងក្រោមជើងទម្រ

អត្ថន័យនៃរូបសញ្ញានេះមានចែងនៅក្នុងឧបសម្ព័ន្ធទី១។

គណបក្សប្រជាធិបតេយ្យជឿនលឿន មានបាវចនា **នីតិរដ្ឋ ភាតរភាព វឌ្ឍនភាព។**

## ឧបសម្ព័ន្ធទី១
## អត្ថន័យនៃរូបសញ្ញា

គណបក្សប្រជាធិបតេយ្យជឿនលឿន មានសញ្ញាសម្គាល់ រូបពន្លឺភ្លើងមានកាំរស្មីលើជើងទម្រ នៅចំកណ្តាលចតុកោណស្មើពណ៌ខៀវ ៖

- ពណ៌ខៀវ តំណាងឱ្យភាពជឿជាក់ សន្តិភាព និងការអភិវឌ្ឍន៍។
- ពន្លឺភ្លើងមានកាំរស្មី តំណាងឱ្យពន្លឺសេរីភាព ប្រជាធិបតេយ្យ និងសេចក្តីសង្ឃឹម
- ប្រជាធិបតេយ្យជឿនលឿន បង្ហាញពីការលើកកម្ពស់ប្រជាធិបតេយ្យ និងភាពរីកចម្រើន ល្អប្រសើរទៅតាមសម័យកាល។

